ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងខេត្តត្បូងឃ្មុំ

តុលាការរដ្ឋប្បវេណី

សំណុំរឿងលេខ៖ ១៣៤

ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០២១

**<u>សាលក្រម</u>**

លេខ៖ ៥៥ "ង"

ចុះថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០២២

# <u>សាលក្រម</u>

## តាងនាមប្រជារាស្ត្រខ្មែរ

## សាលាដំបូងខេត្តត្បូងឃ្មុំ

បានបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់ នាថ្ងៃទី០៤ ខែ ឧសភា ឆ្នាំ ២០២២

និងប្រកាសសាលក្រមជាសាធារណៈ នៅថ្ងៃទី២២ ខែ មិថុនា ឆ្នាំ ២០២១

**<u>ចៅក្រម</u>**

**លោក [redacted] ចៅក្រមសាលាដំបូងខេត្តត្បូងឃ្មុំ**

**<u>ក្រឡាបញ្ជី</u>**

**លោកស្រី [redacted] ក្រឡាបញ្ជីសាលាដំបូងខេត្តត្បូងឃ្មុំ**

**<u>ដើមចោទ៖</u>**

-ឈ្មោះ [redacted] សារឿន ភេទប្រុស កើតនៅថ្ងៃទី០៧ ខែ កញ្ញា ឆ្នាំ១៩៦៨ ជនជាតិ-សញ្ជាតិ ខ្មែរ មុខរបរ ធ្វើស្រែចំការ កាន់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរលេខ [redacted] និងប្រពន្ធឈ្មោះ [redacted] ស កើតនៅថ្ងៃទី ១២ ខែមិថុនា ឆ្នាំ១៩៦៩ ជនជាតិ-សញ្ជាតិខ្មែរ មុខរបរ ធ្វើស្រែចំការ មានអាសយដ្ឋាន៖ [redacted] ។

-<u>មានអ្នកតំណាងដោយអាណត្តិ៖</u>

១-លោកមេធាវី [redacted] នៅការិយាល័យមេធាវី [redacted] អាសយដ្ឋាន [redacted] ។

២-លោកមេធាវី [redacted] អត្តលេខ [redacted] នៅការិយាល័យមេធាវី [redacted] អាសយដ្ឋាន៖ [redacted]។

៣-លោកមេធាវី [redacted] អត្តលេខ [redacted] ការិយាល័យ [redacted]។

**<u>ចុងចម្លើយ៖</u>**

១-ឈ្មោះ [redacted] សុន ភេទប្រុស កើតឆ្នាំ ១៩៧០ ជនជាតិ-សញ្ជាតិ ខ្មែរ មុខរបរ ធ្វើស្រែ និង ប្រពន្ធឈ្មោះ [redacted] ឃឿង ភេទ ស្រី អាយុ៤៩ ឆ្នាំ ជនជាតិ-សញ្ជាតិខ្មែរ មុខរបរ លក់ដូរ, មានអាសយដ្ឋាន៖ [redacted]។

២-ឈ្មោះ [redacted] វណ្ណី ភេទប្រុស កើតឆ្នាំ១៩៩៨ ជនជាតិ-សញ្ជាតិខ្មែរ មុខរបរ ធ្វើចំការ មានអាសយដ្ឋាន [redacted] ។

-<u>អ្នកតំណាងដោយអាណត្តិ៖</u> "គ្មាន" ។

**<u>ខ្លឹមសារនៃសាលក្រម ដែលគូភាគីទាមទារឲ្យតុលាការចេញ៖</u>**

ក/ <u>ខ្លឹមសារនៃសាលក្រមដែលដើមចោទទាមទារឲ្យតុលាការចេញ</u>

១-បង្គាប់ឲ្យចុងចម្លើយប្រគល់ អចលនវត្ថុ (ដីចំការ) ដែលមានវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ 2503080-2223 មកឲ្យដើមចោទ ។

២-បង្គាប់ឲ្យដើមចោទប្រគល់ប្រាក់ថ្លៃខាតបង់ពេលវេលា និងសោហ៊ុយចំណាយផ្សេងៗ មកឲ្យដើមចោទ ចំនួន ២០.០០០ (ពីរម៉ឺន) ដុល្លារអាមេរិកគត់

Scanned with CamScanner

៣-ប្រកាសឲ្យអនុវត្តជាបណ្ដោះអាសន្នចំពោះសាលក្រមខាងលើ ។

៤-ប្រាក់ប្រដាប់ក្ដីជាបន្ទុករបស់ចុងចម្លើយ ។

ខ/ ខ្លឹមសារនៃសាលក្រមដែលចុងចម្លើយទាមទារឲ្យតុលាការចេញ (បណ្ដឹងតប)

-ទាមទារឲ្យដើមចោទឈ្មោះ [redacted] សារឿន និងឈ្មោះ [redacted] ស ចេញសងថ្លៃដំណាំម្រេច និងធុរេនជាប្រាក់ចំនួន ៨០.០០០ (ប្រាំបីម៉ឺន) ដុល្លារអាមេរិក ។

## អង្គហេតុ និងចំណុចវិវាទ

ក/ សង្ខេបអង្គហេតុ៖

នៅអំឡុងឆ្នាំ២០១៦ កូនស្រីរបស់ដើមចោទឈ្មោះ [redacted] សុវណ្ណារី បានរៀបអាពាហ៍ពិពាហ៍ជាមួយចុងចម្លើយ ឈ្មោះ [redacted] វណ្ណី ដែលត្រូវជាកូនរបស់ចុងចម្លើយឈ្មោះ [redacted] សុន និង [redacted] ឃឿង ប៉ុន្តែមិនបានចុះសំបុត្រអាពាហ៍ពិពាហ៍នោះទេ ។ ក្រោយពីរៀបការរួច ដើមចោទដែលជាឪពុកម្ដាយក្មេករបស់ឈ្មោះ [redacted] វណ្ណី បានអនុញ្ញាតឲ្យកូនប្រសារ ឈ្មោះ [redacted] វណ្ណី និងប្រពន្ធ ធ្វើការរៀបចំដាំដំណាំក្នុងចំការដែលជាដីរបស់ខ្លួន មានទំហំ ១១៧៧២m² ម៉ែត្រការ៉េ មានវិញ្ញាបនប័ត្រសំគាល់ម្ចាស់អចលនវត្ថុលេខ ២៥០៣០៨០១-២២២៣ ចុះថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០១៦ របស់មន្ទីរនគររូបនីយកម្ម សំណង់ និងសុរិយោដីខេត្តត្បូងឃ្មុំ ដែលមានទីតាំងស្ថិតនៅភូមិត្រពាំងរាំង ឃុំមេមត់ ស្រុកមេមត់ ខេត្តត្បូងឃ្មុំ ។

រយៈពេល ៥ឆ្នាំកន្លងផុតទៅ ចុងចម្លើយ បានលើកឡើងថា ខ្លួនបានទំនុកបំរុង និងចំណាយ ទឹកប្រាក់អស់ចំនួន ៨០.០០០ (ប្រាំបីម៉ឺន) ដុល្លារអាមេរិក ទៅលើការឈូសឆាយ ភ្ជួររាស់ ការដាំដំណាំ ម្រេច និងធុរេន លើដីខាងលើ ហើយចុងចម្លើយ បានយកដីចំការរបស់ដើមចោទនេះ ទៅកាន់កាប់ ហើយថែមទាំងមិនអោយដើមចោទធ្វើការប្រើប្រាស់ អាស្រ័យផល និងចាត់ចែងលើដីខាងលើបាននេះឡើយ ។

ខ/ ចំណុចវិវាទ៖

ខ.១-អំពីចំណុចវិវាទ

ខ.១.១-តើបណ្ដឹងទាមទារប្រាក់ ចំនួន ៨០.០០០ (ប្រាំបីម៉ឺន) ដុល្លារអាមេរិក លើថ្លៃដំណាំរបស់ចុងចម្លើយ មានមូលហេតុគតិយុត្តត្រឹមត្រូវតាមច្បាប់ដែរ ឬទេ ?

ខ.១.២-តើមានភាពចាំបាច់ដែលត្រូវប្រកាសថា សាលក្រមនេះមានអានុភាពអាច អនុវត្តជាបណ្ដោះអាសន្នឬទេ?

ខ.២-អំពីចំណុចគ្មានវិវាទ

-ដើមចោទ និងចុងចម្លើយទទួលស្គាល់លើអង្គហេតុដែល ដើមចោទបានយល់ព្រមប្រគល់អចលនវត្ថុដែលជាកម្មវត្ថុនៃការទាមទារ ឲ្យទៅភាគីចុងចម្លើយប្រើប្រាស់ និងអាស្រ័យផល ។

-ចុងចម្លើយទទួលស្គាល់អង្គហេតុ លើអចលនវត្ថុដែលជាកម្មវត្ថុនៃការទាមទារ គឺជាកម្មសិទ្ធិស្របច្បាប់របស់ដើមចោទ និងព្រមប្រគល់អោយដើមចោទវិញ (ប៉ុន្តែមានភ្ជាប់លក្ខខ័ណ្ឌ៖ ចំណុចវិវាទ) ។

## ការអះអាងរបស់ភាគីស្ដីពីចំណុចវិវាទ

ក/ ភាគីដើមចោទ៖

-មេធាវីតំណាងដោយអាណត្តិឲ្យដើមចោទ៖ មូលហេតុដែលដើមចោទទាមទារក្នុងពាក្យបណ្ដឹងនូវដីនោះ គឺផ្អែកលើសិទ្ធិលើកម្មសិទ្ធិ។ ចំពោះសំណងចំនួន២ម៉ឺនដុល្លារ គឺដោយសារតែដើមចោទបានចំណាយលើសេវាកម្មច្បាប់ ការខូចខាត និងដោយសារតែសហាចុងចម្លើយប្រើប្រាស់ អាស្រ័យផលលើដីនេះរបស់កូនក្ដីខ្ញុំបាទ។ ចំពោះចំណុចអនុវត្តបណ្ដោះអាសន្ន គឺដោយសារតែកូនក្ដីរបស់ខ្លួន ត្រូវយកដីយកមកប្រើប្រាស់ដើម្បីជីវភាព និង ចំពោះប្រាក់ប្រដាប់ក្ដីដែលជាបន្ទុករបស់ចុងចម្លើយ គឺដោយសារតែជាកំហុសរបស់ចុងចម្លើយ។

ហើយខ្លួនសុំបដិសេធចោលទាំងស្រុងចំពោះបណ្ដឹងតបរបស់ចុងចម្លើយ ពីព្រោះថាការអះអាងរបស់ចុងម្លើយមិនមានភាពសមាមាត្រទេទៅនឹងចំណូលជីវភាព និងការចំណាយប្រចាំថ្ងៃដូចការទាមទាររបស់ចុងចម្លើយ



Scanned with CamScanner

នោះទេ ពីព្រោះចុងចម្លើយត្រូវបង់ធនាគារ និងត្រូវចំណាយលើថ្លៃមើលថែដំណាំ ដូចនេះការអះអាងបែបនេះមិនសមរម្យនោះទេ ។

ស្នើសុំតុលាការពិចារណាច្រានចោលសាក្សីរបស់ចុងចម្លើយ ទាំងអស់ ដោយសារតែសាក្សីទាំងអស់ពុំបានដឹងទីតាំងដែលគាត់ធ្វើការងារនោះទេ ជាពិសេសដីដែលមានវិវាទនេះ ហើយចុងចម្លើយមានទីតាំងចម្ការផ្សេងទៀត ហើយសាក្សីនោះគឺធ្វើការងារស៊ីឈ្នួលអោយចុងចម្លើយគឺនៅទីតាំងចម្ការផ្សេង មិនមែនដីមានវិវាទនេះទេ។ ម៉្យាងវិញទៀតសាក្សីទាំងអស់សុទ្ធតែបានផលលាភពីចុងចម្លើយ។ កូនក្តីរបស់ខ្លួន ជាអ្នកដាំ ចំណែកឯសាក្សីមិនដឹងច្បាស់ថាកន្លែងណាទេដែលបានទៅស៊ីឈ្នួលនោះទេ សូម្បីតែកូនក្តីខ្លួនក៏គាត់មិនដែលជួប ហើយទាំងអ្នកនៅជិតដីនោះក៏គាត់ពុំដែលស្គាល់ដែរ ដូច្នេះសុំអោយតុលាការពិនិត្យសម្រេចតាមពាក្យបណ្តឹងរបស់ខ្លួន។

-ការអះអាងរបស់សាមីដើមចោទ ឈ្មោះ [redacted] សៈ កូនខ្លួនរៀបការជាមួយគ្នា នៅអំឡុងឆ្នាំ២០១៧ ប៉ុន្តែមិនបានចុះសំបុត្រអាពាហ៍ពិពាហ៍នោះទេ។ ចំពោះដីនៅភូមិត្រពាំង ខ្លួនមិនទាន់បានចែកឲ្យកូននោះទេ។ ដីនោះជាប្រភេទដីកសិកម្ម ដោយដំបូងខ្លួនដាំកៅស៊ូ ហើយនៅឆ្នាំ២០១៧ កូនរបស់ខ្លួនបានដាំធុរេន និងម្រេច ។ ពេលការហើយកូនខ្លួនទៅនៅខាងប្រុស ។ ក្រោយរៀបការហើយបាន ០១ឆ្នាំ ទើបខ្លួនសម្រេចចិត្តឲ្យដីទៅកូនរបស់ខ្លួន និងកូនប្រសា ដើម្បីអាស្រ័យផល ។ ខ្លួនបានឲ្យដីនោះជាបណ្តោះអាសន្ននោះទេ ហើយនៅពេលឲ្យដី គឺមានដំណាំកៅស៊ូ ដោយខ្លួនបានដាំយូរហើយ ហើយដល់ពេលប្រមូលផលបានហើយ ។ ដីនោះមានដើមកៅស៊ូចំនួន ៧០០ដើម ។ បន្ទាប់មកខាងជន្លងដែលជាចុងចម្លើយ សុំខ្លួនដើម្បីកាប់កៅស៊ូចោល យកដីដាំធុរ៉េន និងម្រេចវិញ ហើយខ្លួនក៏បានឯកភាព ។ ខ្លួនសូមទាមទារដីនោះមកវិញ ។ ដំណាំធុរ៉េននៅលើដីនោះមានចំនួន ១៦៥ ដើម មានអាយុ ៣-៤ឆ្នាំ, ម្រេច ៩១០ ជន្លង់ ។ ចំណែកឯដំណាំរបស់ខ្លួនមាន ធុរ៉េន ចំនួន ៥ដើម , ម្រេច មានចំនួន ៣០០ ជន្លង់ និងដើមម៉ាក់ប្រេងម៉ាក់ប្រាង ១ដើម ។

នៅពេលដែលខ្លួនឲ្យដីទៅចុងចម្លើយឈ្មោះ [redacted] វណ្ណី អាស្រ័យផលនោះ គឺមានដំណាំដូចជា ធុរ៉េន ចំនួន ១៦០ដើម (តូច,ធំ) ដោយធុរ៉េននោះខ្លះមានអាយុប្រហែល ៤ឆ្នាំ, ៣ឆ្នាំ, ២ឆ្នាំ, និង ១ឆ្នាំ ។ ចំពោះម្រេចវិញ គឺនៅសល់ប្រហែល ២០០ ទេ មានអាយុ ៤ ឆ្នាំ ហើយត្រូវចុងចម្លើយ បានប្រមូលផលយកទាំងអស់។ ចុងចម្លើយបានប្រមូលផលចំនួនប្រាំមួយឆ្នាំហើយ។ កូនស្រីរបស់ខ្លួន និងខ្លួនគឺមិនដែលបានទទួលផលអ្វីទេ គឺចុងចម្លើយប្រមូលផលយកទាំងអស់ ដោយមិនដែលអោយមកខ្លួនដែលជាម្ចាស់កម្មសិទ្ធិលើដីនោះទេ ។

កន្លងមកដោយសារតែខ្លួនមិនចង់អោយកូនបែកបាក់គ្នា ទើបបន្តអោយចុងចម្លើយប្រមូលផលរហូតមកដល់សព្វថ្ងៃនេះ តែកូនស្រីរបស់ខ្លួន និងចុងចម្លើយមិនរស់នៅមិនសុខនឹងគ្នា ទើបខ្លួនទាមទារដីមកវិញ។ ដីនោះគឺខ្លួនបានអោយកូនស្រីរបស់ខ្លួនឈ្មោះ សុវណ្ណារី ទេ ហើយកូនខ្លួនក៏ជាអ្នកដាំដំណាំនៅលើដីនោះដែរ មិនមែនខាងសហាចុងចម្លើយចូលទៅដាំនោះទេ។ ចំពោះដំណាំវិញ គឺទាល់តែប្រើរយៈពេលពី៣ទៅ៥ឆ្នាំ ទើបទទួលបានផល។ ចំពោះដំណាំម្រេច ចុងចម្លើយប្រមូលផលបាន ៤ ឆ្នាំហើយ ហើយចុងចម្លើយប្រមូលផលទាំងអស់ដោយពុំដែលបានឲ្យមកកូនស្រីរបស់ខ្លួនឡើយ ។

ខ/ <u>ភាគីចុងចម្លើយ៖</u>

-ការអះអាងរបស់ចុងចម្លើយ ឈ្មោះ [redacted] ឃឿង៖ ពេលដែលដើមចោទឲ្យដីនោះ គឺជាដីទទេ មិនឃើញមានដាំដំណាំអ្វីទេ។ ពេលដែលដើមចោទអោយដីមកភ្លាម ខ្លួបបានដាំធុរ៉េនប្រហែល ២០០ ដើម ឥលូវនៅសល់ប្រហែល ១៧០ ដើម មានអាយុ ៤ ទៅ ៥ឆ្នាំ។ ចំពោះម្រេច ដាំដំបូងមានចំនួន ១១០០ ដើម តែងាប់អស់សល់ប្រហែល ៣ទៅ៤ រយដើម ហើយមានអាយុប្រហែល ៥ ចូល ៦ ឆ្នាំហើយ។ ខ្លួនបានប្រមូលផលម្រេចបាន ៤ដងហើយ ប្រហែលបានលុយ ៥ ទៅ ៦ លានរៀល។ ប្រាក់ ១២ លាន រៀល ខ្លួនបានចំណាយលើពូជកូនធុរ៉េនក្នុងមួយដើម ៦ម៉ឺនរៀល ហើយកូនធុរ៉េនមានចំនួន ២០០ដើម។ ចំណែកឯ ម្រេចវិញ ខ្លួនចំណាយអស់ ៦០.៥០០.០០០ (ហុកសិបលាន ហាសិបម៉ឺន) រៀល ។ ចំពោះ ពូជម្រេចខ្លួនមិនបានយកពីដណ្តាំងជាដើមចោទទេ គឺជាពូជខ្លួនឯងទេ ។ ខ្លួនយកម្រេច ៦០ ជន្លង់ ពីដើមចោទ តែកាត់កងជាមួយថ្លៃស្ប្បែចហើយ។ ខ្លួន



Scanned with CamScanner

ចំណាយក្នុងមួយខែចំនួន ១.៥០០.០០០ (មួយលានហាសិបម៉ឺន) រៀល ក្នុងការចំណាយជួលគេ និងមកថែដីដាំណាំនោះ។ ការដាក់ជី និងបាញ់ថ្នាំ ក្នុង១ឆ្នាំចំណាយអស់ ៩.០០០.០០០ (ប្រាំបួនលាន) រៀល។ ប្រេងម៉ាស៊ូតទុកសម្រាប់បាញ់ទឹក ១ខែប្រើអស់បីកាដុង ចំណាយុយអស់ ២៥ម៉ឺនរៀលក្នុងមួយខែ។ សរុបថ្លៃដែលទាមទារ គឺ ៨០.០០០ (ប្រាំបីម៉ឺន) ដុល្លារអាមេរិក ។

គ/ <u>ការបំភ្លឺរបស់សាក្សី៖</u>

គ.១/ សាក្សីភាគីដើមចោទ៖

១/ ឈ្មោះ [redacted] សាំ ជាសាក្សីបំភ្លឺថា៖ ខ្លួនសូមនិយាយការពិត ខ្លួនបានដឹងថាឈ្មោះ [redacted] ស បានព្រមព្រៀងអោយដីទៅកូនស្រីបង្កើត និងកូនប្រសាររបស់គាត់កាន់កាប់។ ហើយឈ្មោះ [redacted] ស មិនបានព្រមព្រៀងអោយទៅចុងចម្លើយនោះទេ។ ខ្លួនមិនបានដឹងថាពេលដែលចុងចម្លើយជាឪពុកម្ដាយក្មេកមកដាំដំណាំលើដីនោះ គាត់បានទៅសុំដើមចោទជាបងស្រីរបស់ខ្លួនដែរ ឬអត់នោះទេ។ ចុងចម្លើយបានដាំម្រេចចំនួន ៩១៤ ជន្លង់ មានអាយុប្រហែល ៥ឆ្នាំហើយគិតមកដល់សព្វថ្ងៃ។ ខ្លួនក៏ធ្លាប់ដាំម្រេចផងដែរ ហើយខ្លួនដាំម្រេចប្រហែលជា ១២០០ ជន្លង់ ដោយរាប់ទាំងការទិញដីផង និងដាំម្រេចផង គឺអស់ប្រហែលជាង១ម៉ឺនដុល្លារ ពោលគឺ ១៥០០០ (មួយម៉ឺនប្រាំពាន់) ដុល្លារអាមេរិក ដោយរួមបញ្ចូលទាំងការចំណាយលើការថែទាំដូចជា បាញ់ថ្នាំ ប្រេងម៉ាស៊ូតដើម្បីស្រោចដំណាំផងដែរ ។ ដាំម្រេចមួយជន្លង់ អស់ប្រហែល ២៥០០០(ពីរម៉ឺនប្រាំពាន់) រៀល ។

២/ ឈ្មោះ [redacted] សុខសាន្ត បំភ្លឺថា៖ ខ្លួនត្រូវជាកូនស្រីរបស់ឈ្មោះ [redacted] ស ។ ចំពោះរឿងដីនោះខ្លួនមិនបានដឹងទេ។ តាមដែលខ្លួនធ្លាប់ដាំម្រេចគឺក្នុងមួយជន្លង់ចំណាយអស់ប្រហែល ១២០០០ (មួយម៉ឺនពីរពាន់) រៀល ។ ចំពោះការចំណាយទៅលើការថែទាំម្រេច គឺមិនសូវចំណាយច្រើននោះទេ ។ តាមដែលខ្លួនធ្លាប់ដាំម្រេច គឺប្រើរយៈពេល ៣ ឆ្នាំទើបបានប្រមូលផល។ ចំពោះធុរេន ខ្លួនធ្លាប់ដាំប្រហែល ២០ កូន ក្នុងមួយកូនតម្លៃ ១៧០០០ (មួយម៉ឺនប្រាំពីរពាន់) រៀល ខ្លួនដាំដោយខ្លួនឯង ចំពោះការថែទាំក៏មិនមានការពិបាកថែទាំអ្វីនោះដែរ ។

គ.២/ សាក្សីភាគីចុងចម្លើយ៖

១/ ឈ្មោះ [redacted] សារ៉ុន បំភ្លឺថា៖ ខ្លួនជាអ្នកស៊ីឈ្នួលដាំ និងបេះដំណាំអោយចុងចម្លើយ ដោយទៅធ្វើការប្រហែល ៥ទៅ ៦ នាក់ក្នុងមួយថ្ងៃ។ ចុងចម្លើយអោយថ្លៃឈ្នួល ៣៥០០០ រៀល ក្នុងមួយថ្ងៃ ។ ចំពោះម្រេច និងធុរេន ខ្លួនក៏មិនដឹងថាមានប៉ុន្មានដើមនោះដែរ។ ខ្លួនទៅបេះម្រេច បានច្រើនដងដែរ ហើយបេះបានពីរ ទៅ បីឆ្នាំមកហើយ ដោយក្នុងមួយឆ្នាំបេះបានប្រហែលបីដង ហើយបេះបានពីរឆ្នាំ សរុបចំនួន ៦ដង។ ខ្លួនបេះក្នុងមួយគីឡូបានថ្លៃឈ្នួលចំនួន ៨០០ (ប្រាំបីរយ) រៀល។ ការស៊ីឈ្នួលក្នុងម្នាក់ប្រហែលបាន ៤ (បួន) ទៅ ៥ (ប្រាំ) ម៉ឺនរៀល។ ចំពោះដាំណាំធុរេន មិនទាន់មានផ្លែទេ។ ខ្លួនមិនធ្លាប់ដែលដាំម្រេច និងធុរេនទេ ហើយក្រៅពីស៊ីឈ្នួលអោយចុងចម្លើយខ្លួនធ្លាប់ស៊ីឈ្នួលអោយគេផ្សេងដែរ ហើយបានតម្លៃប្រហែលគ្នា។ ខ្លួនស៊ីឈ្នួលយូរដែរហើយ។ ខ្លួនមិនចាំថាចុងចម្លើយបានដាំម្រេចជន្លង់ និងធុរេនប៉ុន្មានដើមទេ ហើយក៏មិនបានដឹងថាគាត់លក់បានតម្លៃប៉ុន្មាននោះដែរ ។

២/ ឈ្មោះ [redacted] អេន បំភ្លឺថា៖ ខ្លួនស៊ីឈ្នួលជម្រះស្មៅ និងអុំជីអោយចុងចម្លើយ ហើយខ្លួនធ្វើការបានប្រហែល ៥ឆ្នាំហើយ។ ខ្លួនទៅជម្រះស្មៅមួយខែ ៥ទៅ ៦ដង បានថ្លៃឈ្នួលចំនួន ៣ (បី) ម៉ឺនរៀលក្នុងមួយថ្ងៃ។ ខ្លួនមិនដឹងថាម្រេចមានប៉ុន្មានជន្លង់នោះទេហើយចំណែកឯធុរេនក៏មិនបានដឹងថាមានប៉ុន្មានដើមដែរ។

ខ្លួនមិនចាំឆ្នាំធ្វើការពីឆ្នាំណាដល់ឆ្នាំណាទេ ហើយក៏មិនចាំទីតាំងដីនៅទីណាដែរ។ ហើយខ្លួនបានលឺថាដីនោះមានទំនាស់រឿងដី ខ្លួនមិនបានដឹងថាមានអ្នកណាខ្លះនៅជិតដីនោះទេ។ តាំងពីធ្វើការមកបានប្រាក់ចំនួនប្រហែល ៩០ (កៅសិប) ម៉ឺនរៀលក្នុងមួយខែ ហើយក្នុងមួយថ្ងៃបាន ៣ (បី) ម៉ឺនរៀល ។ ក្នុងមួយខែ ប្រសិនបើធ្វើការពេញធ្វើការបាន ៣០ថ្ងៃ។ ខ្លួនជម្រះស្មៅពេលព្រឹក ពីម៉ោង ៨ ដល់ ១០ ពេលរសៀល ពីម៉ោង ១ដល់ម៉ោង ៤។ ខ្លួនធ្វើការក្នុងផ្ទះផង និងនៅចម្ការផង។ ចំពោះពេលធ្វើការនៅក្នុងផ្ទះបានប្រហែល ៣ម៉ឺនរៀលក្នុងមួយថ្ងៃ ហើយធ្វើនៅចម្ការបាន ៣ (បី)ម៉ឺនរៀល ក្នុងមួយថ្ងៃ។

៣/ ឈ្មោះ [redacted] ញ៉ាញ់ បំភ្លឺថា៖ ខ្លួនជាអ្នកស៊ីឈ្នួលជម្រះស្មៅអោយចុងចម្លើយ។ ជម្រះស្មៅក្នុងមួយខែប្រហែល បី ទៅ បួន ដង ជម្រះម្តងបានតម្លៃ ៣ ម៉ឺនរៀល។ ខ្លួនមិនដែលបានឃើញចុងចម្លើយបាញ់ថ្នាំលើដីចម្ការនោះទេ។ ខ្លួនធ្វើការពីឆ្នាំ ២០២១ ខែកក្កដា ដោយធ្វើការមួយខែបាន ពីរ បី ទៅ បួន ដង។ ខ្លួនមិនស្គាល់ផ្ទះរបស់ដើមចោទថានៅទីណាទេ។ ចំពោះថ្លៃធ្វើដំណើរមកតុលាការខាងចុងចម្លើយជាអ្នកចំណាយអោយទាំងអស់។

៤/ ឈ្មោះ [redacted] ធារ៉ា បំភ្លឺថា៖ ចុងចម្លើយជាអ្នកហៅខ្លួនមកធ្វើជាសាក្សី ។ ខ្លួនស៊ីឈ្នួលកាត់ស្មៅបានច្រើនដងដែរ បានប្រហែល ៣ដងហើយ ដោយយូរៗខ្លួនទៅកាត់ស្មៅម្តង សរុបទាំងអស់បាន ៣ ដង ។ កាត់ស្មៅហើយអស់មួយចម្ការបានប្រាក់ប្រហែល ១៥(ដប់ប្រាំ) ម៉ឺនរៀល ដោយមានគ្នាកាត់ ២នាក់។ ដីដែលខ្លួនទៅស៊ីឈ្នួលកាត់ស្មៅនោះមានទំហំធំដែរ។ ខ្លួនមិនបានរាប់ចំនួនដើមធុរេន និង ម្រេច ថាមានចំនួនប៉ុន្មាននោះទេ។ ក្រៅពីស៊ីឈ្នួលកាត់ស្មៅ ខ្លួនមិនធ្វើអ្វីផ្សេងទេ។ ដីដែលខ្លួនទៅស៊ីឈ្នួលខាងលើគឺស្ថិតនៅត្រពាំងរាំង ខ្លួនទៅកាត់ស្មៅបាន ៣ ដងហើយ ខ្លួនធ្វើការស៊ីឈ្នួលតាំងពីឆ្នាំមុន ។ នៅក្បែរទីតាំងដីនោះមានផ្ទះនៅជិតនោះដែរ នៅក្នុងដីមានតែម្រេច និងធុរេន ទេ មិនមានអ្វីនៅលើដីនោះផ្សេងទៀតទេ។

៥/ ឈ្មោះ [redacted] ធាត់ បំភ្លឺថា៖ ចុងម្លើយជាអ្នកហៅខ្លួនឲ្យមកធ្វើជាសាក្សី។ ខ្លួនធ្លាប់ស៊ីឈ្នួលអោយចុងចម្លើយប្រហែល ៥ ឆ្នាំហើយ តែធ្វើការមិនជាប់ទេ។ ខ្លួនមិនចាំថាក្នុងមួយខែទៅធ្វើការប៉ុន្មានដងទេ។ ខ្លួនបាញ់ថ្នាំក្នុងមួយថ្ងៃ បានប្រាក់ប្រហែល ៦ (ប្រាំមួយ) ម៉ឺនរៀល ប្រសិនបើម៉ៅតែម្តងគឺបាន ៧(ប្រាំពីរ) ម៉ឺនរៀល។ ជួនកាលក្នុងមួយថ្ងៃ ឬមួយថ្ងៃកន្លះ ខ្លួនបាញ់ថ្នាំរួច ហើយខ្លួនទៅធ្វើការម្តងបានប្រាក់ពី ៧ (ប្រាំពីរ) ទៅ១០(ដប់) ម៉ឺនរៀល។ ចំពោះថ្នាំសម្រាប់បាញ់ម្រេច កន្លះខែបាញ់ម្តង ជួនកាលមួយអាទិត្យ ឬមួយខែទើបបាញ់ម្តង ប៉ុន្តែខ្លួនមិនច្បាស់ទេ។ ចំពោះថ្លៃហូបចុក និងថ្លៃធ្វើដំណើរ គឺបងរបស់ខ្លួនដែលជាចុងចម្លើយជាអ្នកចេញអោយ។ ខ្លួនមិនបានដឹងថាមានចុងចម្លើយមានចម្ការប៉ុន្មានកន្លែងទេ ហើយចំពោះទីតាំងដីក៏មិនបានដឹងថានៅទីណាដែរ ។

## <u>សំអាងហេតុ</u>

### ក-<u>ការវិនិច្ឆ័យលើចំណុចវិវាទ</u>

១-<u>ចំពោះចំណុចវិវាទទី១</u> លើអត្ថិភាព ឬ នត្ថិភាព ចំពោះការទាមទារប្រាក់ ចំនួន ៨០.០០០ (ប្រាំបីម៉ឺន) ដុល្លារអាមេរិក លើថ្លៃដំណាំរបស់ចុងចម្លើយ តុលាការយល់ឃើញថា៖ នៅអំឡុងឆ្នាំ២០១៦ កូនស្រីរបស់ដើមចោទឈ្មោះ [redacted] សុវណ្ណារី បានរៀបអាពាហ៍ពិពាហ៍តាមប្រពៃណីជាមួយចុងចម្លើយ ឈ្មោះ [redacted] វណ្ណី ដែលត្រូវជាកូនរបស់ចុងចម្លើយឈ្មោះ [redacted] សុន និងឈ្មោះ [redacted] ឃឿង ។ ក្រោយពីរៀបការរួច ដើមចោទ បានអនុញ្ញាតឲ្យភាគីចុងចម្លើយ ធ្វើការរៀបចំដាំដំណាំ (ម្រេច និងធុរេន) ក្នុងចំការដែលជាដីរបស់ខ្លួន មានទំហំ ១១៧៧២$m^2$ ម៉ែត្រការ៉េ មានវិញ្ញាបនប័ត្រសំគាល់ម្ចាស់អចលនវត្ថុ លេខ ២៥០៣០៨០១-២២២៣ ចុះថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ ២០១៦ របស់មន្ទីរនគររូបនីយកម្ម សំណង់ និងសុរិយោដីខេត្តត្បូងឃ្មុំ ដែលមានទីតាំងស្ថិតនៅភូមិត្រពាំងរាំង ឃុំមេមត់ ស្រុកមេមត់ ខេត្តត្បូងឃ្មុំ ដោយមិនយកថ្លៃឈ្នួល និងមិនបានកំណត់អំឡុងពេល នោះទេ ។

រយៈពេល ៥ឆ្នាំកន្លងផុតទៅ ភាគីចុងចម្លើយ បានលើកឡើងថា ខ្លួនបានទំនុកបំរុង និងចំណាយ ទឹកប្រាក់អស់ ចំនួន ៨០.០០០ (ប្រាំបីម៉ឺន) ដុល្លារអាមេរិក ទៅលើការឈូសឆាយ ភ្ជួររាស់ ការដាំដំណាំ ម្រេច និងធុរេន លើដីខាងលើ ហើយចុងចម្លើយ បានយកដីចំការរបស់ដើមចោទនេះ ទៅកាន់កាប់ ហើយថែមទាំងមិនអោយដើមចោទ ធ្វើការប្រើប្រាស់ អាស្រ័យផល និងចាត់ចែងលើដីខាងលើបាននេះឡើយ ។

*យោងមាត្រា ២៥៦ នៃក្រមរដ្ឋប្បវេណី (និយមន័យនៃផលុបភោគ) បានចែងថា៖*

*១-ផលុបភោគ សំដៅទៅលើសិទ្ធិប្រើប្រាស់ និង អាស្រ័យផលលើអចលនវត្ថុ ដែលជាកម្មសិទ្ធិរបស់អ្នកដទៃ ក្នុងអំឡុងពេលកំណត់ណាមួយដែលមិនអាចលើសពីមួយ ជីវិតរបស់ផលុបភោគី ។*

*២-ផលុបភោគីមានសិទ្ធិប្រើប្រាស់អចលនវត្ថុដែលជាកម្មវត្ថុនៃផលុបភោគ តាមវិធីប្រើប្រាស់ និង មានសិទ្ធិអាស្រ័យផលធម្មជាតិ និង ផលស៊ីវិលដែលកើតចេញពី អចលនវត្ថុនោះ ។*



Scanned with CamScanner

*មាត្រា ២៥៧ ចំណុចលេខ១ នៃក្រមរដ្ឋប្បវេណី (ផលុបភោគដែលកំណត់ដោយការព្រមព្រៀង និងផលុបភោគដែលច្បាប់បានកំណត់) បានចែងថា៖*

*១-ផលុបភោគ ត្រូវបានបង្កើតឡើងដោយការព្រមព្រៀងរវាងភាគី ឬ ដោយបញ្ញត្តិនៃច្បាប់ ។*

*មាត្រា ២៥៨ ចំណុចលេខ១ នៃក្រមរដ្ឋប្បវេណី (ការបង្កើតផលុបភោគ) បានចែងថា៖*

*១-ផលុបភោគអាចបង្កើតតាមលិខិតជាលាយល័ក្ខណ៍អក្សរ ឬមិនតាមលិខិតជាលាយល័ក្ខណ៍អក្សរបាន។*

យោងតាមអង្គហេតុខាងលើ ដើមចោទបានអនុញ្ញាត និងព្រមព្រៀងដោយផ្ទាល់មាត់ អោយចុងចម្លើយមានសិទ្ធិប្រើប្រាស់ និង អាស្រ័យផលលើអចលនវត្ថុរបស់ខ្លួន ដោយមិនបានកំណត់អំឡុងពេលណាមួយទេ ។ ហើយចុងចម្លើយ (ផលុបភោគី) ក្រោយពីបានទទួលអចលនវត្ថុ ដែលមានវិញ្ញាបនប័ត្រសំគាល់ម្ចាស់អចលនវត្ថុលេខ ២៥០៣០៨០១-២២២៣ ចុះថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០១៦ របស់មន្ទីរនគររូបនីយកម្ម សំណង់ និងសុរិយោដីខេត្តត្បូងឃ្មុំ ដែលមានទីតាំងស្ថិតនៅភូមិត្រពាំងរាំង ឃុំមេមត់ ស្រុកមេមត់ ខេត្តត្បូងឃ្មុំ ពីដើមចោទ (កម្មសិទ្ធិករ) រួចហើយ បានប្រើប្រាស់អចលនវត្ថុដែលជាកម្មវត្ថុនៃផលុបភោគ តាមវិធីប្រើប្រាស់ និង អាស្រ័យផលធម្មជាតិ និង ផលស៊ីវិលដែលកើតចេញពី អចលនវត្ថុនោះ ដោយធ្វើការដាំដុះដំណាំ ម្រេច និងធុរេន ។

តាមរយៈអង្គហេតុ និងបទបញ្ញត្តិខាងលើនេះតុលាការអាចកំណត់ទំនាក់ទំនងគតិយុត្តរវាងដើមចោទ និងចុងចម្លើយ បានគឺ "ផលុបភោគ" (*មិនតាមលិខិតជាលាយល័ក្ខណ៍អក្សរ*) ។

យោងអង្គហេតុ ដើមចោទ (កម្មសិទ្ធិករ) បានទាមទារឲ្យចុងចម្លើយប្រគល់មកខ្លួនវិញនូវ អចលនវត្ថុ ជាកម្មវត្ថុនៃផលុបភោគ ដែលមានវិញ្ញាបនប័ត្រសំគាល់ម្ចាស់អចលនវត្ថុ លេខ ២៥០៣០៨០១-២២២៣ ចុះថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០១៦ របស់មន្ទីរនគររូបនីយកម្ម សំណង់ និងសុរិយោដីខេត្តត្បូងឃ្មុំ ដែលមានទីតាំងស្ថិតនៅភូមិត្រពាំងរាំង ឃុំមេមត់ ស្រុកមេមត់ ខេត្តត្បូងឃ្មុំ ដោយមានការដោះស្រាយគ្នាក្រៅប្រព័ន្ធតុលាការជាច្រើនលើកច្រើនសារ តាំងពីមិនទាន់ដាក់ពាក្យបណ្តឹងមកតុលាការ ។

*យោងតាម កថាខណ្ឌទី២ ចំណុច ខ និងកថាខណ្ឌទី៣ នៃមាត្រា ២៥៨ ការបង្កើតផលុបភោគ បានចែងថា៖*

*"២- កម្មសិទ្ធិករអាចស្នើសុំឱ្យរំលត់ផលុបភោគ ដែលមិនធ្វើតាមលិខិតជាលាយល័ក្ខណ៍អក្សរ នៅពេលណាក៏បាន ។ ក្នុងករណីដែលការស្នើសុំឱ្យរំលត់ មិនបានបញ្ជាក់អំពី ពេលរលត់ និង ក្នុងករណីដែលអំឡុងពេលគិតចាប់ពីពេលស្នើសុំឱ្យរំលត់ រហូតដល់ពេល រលត់ដែលបានបញ្ជាក់នៅក្នុងការស្នើសុំឱ្យរំលត់នោះ តិចជាងអំឡុងពេលដូចបានកំណត់ ខាងក្រោមនេះ ផលុបភោគត្រូវរលត់ នៅពេលដែលអំឡុងពេលដូចបានកំណត់ខាងក្រោមនេះ បានកន្លងហួស គិតចាប់ពីពេលស្នើសុំឱ្យរំលត់៖ ខ- ១ (មួយ) ឆ្នាំចំពោះដី ។*

*"៣- ចំពោះផលុបភោគដីដែលមានរដូវប្រមូលផល ការស្នើឱ្យរំលត់ត្រូវធ្វើនៅមុនពេលដែលផលុបភោគីចាប់ផ្តើមការងារកសិកម្ម សម្រាប់រដូវបន្ទាប់ពីរដូវមុន ។*

*មាត្រា ១៥៥ វាក្យខណ្ឌទី១ នៃក្រមរដ្ឋប្បវេណី (សិទ្ធិទាមទារឲ្យប្រគល់វិញដោយផ្អែកលើសិទ្ធិនៃកម្មសិទ្ធិ) បានចែងថា៖ កម្មសិទ្ធិករអាចទាមទារឲ្យអ្នកកាន់កាប់ប្រគល់វត្ថុរបស់ខ្លួនវិញបាន ។*

តាមរយៈអង្គហេតុ និងបទបញ្ញត្តិខាងលើនេះ តុលាការអាចកំណត់បានថា "ផលុបភោគត្រូវបានរលត់" នាំឲ្យកម្មសិទ្ធិករ (ដើមចោទ) មានសិទ្ធិទាមទារឲ្យប្រគល់វិញនូវ អចលនវត្ថុ ដែលមានវិញ្ញាបនប័ត្រសំគាល់ម្ចាស់អចលនវត្ថុ លេខ ២៥០៣០៨០១-២២២៣ ចុះថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០១៦ របស់មន្ទីរនគររូបនីយកម្ម សំណង់ និងសុរិយោដីខេត្តត្បូងឃ្មុំ ដែលមានទីតាំងស្ថិតនៅ ភូមិត្រពាំងរាំង ឃុំបេបត់ ស្រុកបេបត់ ខេត្តត្បូងឃ្មុំ ដោយផ្អែកលើសិទ្ធិនៃកម្មសិទ្ធិរបស់ខ្លួន ។

យោងអង្គហេតុ ចុងចម្លើយ បានទាមទារឲ្យដើមចោទប្រគល់ប្រាក់ ចំនួន ៨០.០០០ (ប្រាំបីម៉ឺន) ដុល្លាអាមេរិច មកឲ្យខ្លួន ទើបខ្លួនព្រមប្រគល់អចលនវត្ថុ ដែលមានវិញ្ញាបនប័ត្រសំគាល់ម្ចាស់អចលនវត្ថុ លេខ ២៥០៣០៨០១-២២២៣ ចុះថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០១៦ របស់មន្ទីរនគររូបនីយកម្ម សំណង់ និងសុរិយោដីខេត្ត



Scanned with CamScanner

ត្បូងឃ្មុំ ដែលមានទីតាំងស្ថិតនៅ ភូមិត្រពាំងរាំង ឃុំមេមត់ ស្រុកមេមត់ ខេត្តត្បូងឃ្មុំ ឲ្យទៅដើមចោទវិញ ។ ហើយក្នុងអំឡុងពេលផលុបភោគមានអត្ថិភាព ចុងចម្លើយក៏បានទទួលស្គាល់ផងដែរថា ខ្លួនបានទទួលផលពីដំណាំទាំងនោះផងដែរ ។

*យោងមាត្រា ២៦១ ចំណុចលេខ១ និង២ នៃក្រមរដ្ឋប្បវេណី (សិទ្ធិអាស្រ័យផលធម្មជាតិ) បានចែងថា៖*

*១-ផលធម្មជាតិដែលមានអត្ថិភាពលើដី នៅពេលបង្កើតផលុបភោគ ត្រូវបានទៅ ផលុបភោគី ។*

*២-ផលធម្មជាតិដែលមានអត្ថិភាពលើដី នៅពេលផលុបភោគរលត់ ត្រូវបានទៅ កម្មសិទ្ធិករនៃដី ។*

*មាត្រា ២៦៩ ចំណុចលេខ២ នៃក្រមរដ្ឋប្បវេណី (អានុភាពនៃការរំលត់ផលុបភោគ) បានចែងថា៖*

*"២"-ប្រសិនបើផលុបភោគបានរលត់ កម្មសិទ្ធិករអចលនវត្ថុ អាចទទួលកម្មសិទ្ធិលើការដែលបានកែលំអ ឬ សំណង់ ជាអាទិ៍ ដែលផលុបភោគី បានធ្វើចំពោះអចលនវត្ថុ ដោយគ្មានសងប្រាក់សំណងទៅផលុបភោគី ឬ សន្តតិជនរបស់អ្នកនោះ ។*

តាមរយៈអង្គហេតុ និងបទបញ្ញត្តិខាងលើនេះបង្ហាញថា ផលុបភោគី (ចុងចម្លើយ) មិនអាចទាមទារប្រាក់សំណងពី កម្មសិទ្ធិករ (ដើមចោទ) បានទេ ហេតុដូច្នេះ គប្បីតុលាការសម្រេចច្រានចោលការទាមទារក្នុងបណ្ដឹងតបរបស់ចុងចម្លើយ ។

២-<u>ចំពោះចំណុចវិវាទទី២៖</u> លើអត្ថិភាព ឬ នត្ថិភាព នៃភាពចាំបាច់សម្រាប់ការប្រកាសសាលក្រមឲ្យអនុវត្តជាបណ្ដោះអាសន្ន តុលាការយល់ឃើញថា៖ ការទាមទាររបស់ដើមចោទមានភាពចាំបាច់ គឺដើម្បីជៀសវាងការខូចខាតប្រយោជន៍ដល់ដើមចោទ ហើយការទាមទារឲ្យប្រគល់អចលនវត្ថុ មានវិញ្ញាបនប័ត្រសំគាល់ម្ចាស់អចលនវត្ថុ លេខ ២៥០៣០៨០១-២២២៣ ខាងលើនេះ គឺមានឈ្មោះរបស់ដើមចោទជាកម្មសិទ្ធិករយ៉ាងច្បាស់លាស់ ម្យ៉ាងវិញទៀត ចុងចម្លើយក៏បានទទួលស្គាល់ចំពោះការទាមទាររបស់ដើមចោទនេះដែរ វាគឺជាសក្ខីកម្មមួយ ដែលបញ្ជាក់ច្បាស់លាស់ អំពីអត្ថិភាពនៃសិទ្ធិទាមទាររបស់ដើមចោទ លើអចលនវត្ថុ ដែលនឹងពុំមានការប្រែប្រួលអ្វីឡើយ ដូច្នេះគប្បីតុលាការ ប្រកាសថា សាលក្រមនេះអាចអនុវត្តជាបណ្ដោះអាសន្នបានលើការទាមទារឲ្យប្រគល់នេះ ដោយពុំចាំបាច់ឲ្យដាក់ប្រាតិភោគ ស្របតាមមាត្រា ១៩៦ នៃក្រមនីតិវិធីរដ្ឋប្បវេណី ។

**ខ-<u>ការវិនិច្ឆ័យអំពីប្រាក់សំណងការខាតបង់ពេលវេលា និងសោហ៊ុយចំណាយផ្សេងៗ</u>**

ដោយមូលហេតុដែលជាកំហុសរបស់ចុងចម្លើយ ទើបធ្វើឲ្យដើមចោទឈានដល់ការដាក់ពាក្យបណ្ដឹងទាមទារឲ្យប្រគល់អចលនវត្ថុនេះ ។ ក្នុងដំណើរការនីតិវិធីនៃបណ្ដឹងជាការពិតណាស់ដើមចោទបានចំណាយទាំងពេលវេលា និងប្រាក់ចំណាយលើការធ្វើដំណើរ ហូកចុក និងសោហ៊ុយពឹងពាក់មេធាវីជាដើម ។ ហេតុដូច្នេះ គប្បីតុលាការពិចារណា និងសម្រេច តាមការខូចខាត ព្យសនកម្មជាក់ស្ដែង គោលការណ៍សមធម៌ ស្ថានភាពជីវភាពសេដ្ឋកិច្ច និងដោយគិតពិចារណាអំពីកាលៈទេសៈជុំវិញផ្សេងៗ ។

**គ-<u>ការវិនិច្ឆ័យអំពីបន្ទុកប្រដាប់ក្ដី</u>**

ក្នុងរឿងក្ដីនេះ ភាគីចុងចម្លើយជាអ្នកមានកំហុស និងជាអ្នកចាញ់ក្ដី ដែលបានបំពានច្បាប់ក្នុងការអនុវត្តកាតព្វកិច្ចរបស់ខ្លួន ដូច្នេះ ភាគីចុងចម្លើយត្រូវតែទទួលបន្ទុកចំពោះប្រាក់ប្រដាប់ក្ដី យោងតាមមាត្រា ៦៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

## <u>សេចក្ដីសម្រេចបញ្ចប់</u>

**ក/ <u>បង្គាប់ឲ្យចុងចម្លើយ៖</u>**

១-ឈ្មោះ [redacted] សុន និងប្រពន្ធឈ្មោះ [redacted] ឃ្លៀង និងឈ្មោះ [redacted] វណ្ណី៖

ប្រគល់អចលនវត្ថុ (ដីចំការ) ស្ថិតនៅភូមិត្រពាំងរាំង ឃុំមេមត់ ស្រុកមេមត់ ខេត្តត្បូងឃ្មុំ ដែលមានវិញ្ញាបនប័ត្រសម្គាល់ម្ចាស់អចលនវត្ថុ លេខ ២៥០៣០៨០១-២២២៣ ចុះថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០១៦ របស់មន្ទីររៀបចំដែនដី នគររូបនីយកម្ម សំណង់ និងសុរិយោដី ខេត្តត្បូងឃ្មុំ ឲ្យទៅដើមចោទ៖ ឈ្មោះ [redacted] សារឿន និងប្រពន្ធឈ្មោះ [redacted] ស



Scanned with CamScanner

២-ឈ្មោះ [redacted] សុន និងប្រពន្ធឈ្មោះ [redacted] ឃឿង និងឈ្មោះ [redacted] វណ្ណី៖
រួមគ្នាសងដោយកាតព្វកិច្ចសាមគ្គី ឲ្យទៅដើមចោទ៖ ឈ្មោះ [redacted] សារឿន និងប្រពន្ធឈ្មោះ [redacted] ស នូវសំណងខាតបង់ពេលវេលា និងសោហ៊ុយចំណាយផ្សេងៗជាប្រាក់ ចំនួន ៦.០០០.០០០ (ប្រាំមួយលាន) រៀល

**ខ/ <u>សម្រេចច្រានចោល៖</u>**

១- ការទាមទារលើសពីនេះរបស់ដើមចោទ ។

២- ការទាមទាររបស់ចុងចម្លើយ ក្នុងពាក្យបណ្តឹងតប ចុះថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០២១ ។

សាលក្រមនេះ ត្រូវបានប្រកាសជាសាធារណៈនៅថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០២២។ ក្នុងករណីមានបណ្តឹងឧទ្ធរណ៍ត្រូវធ្វើឡើងក្នុងរយៈពេល ០១ (មួយ) ខែ គិតចាប់ពីថ្ងៃដែលទទួលបាននូវលិខិតបញ្ជូនសាលក្រមនេះ ។

ថ្ងៃពុធ ៨រោច ខែជេស្ឋ ឆ្នាំខាល ចត្វាស័ក ព.ស ២៥៦៦
ខេត្តត្បូងឃ្មុំ ថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០២២
**<u>ចៅក្រម</u>**
**ហត្ថលេខា និងត្រា៖** [redacted]

---

បានចម្លងចេញត្រឹមត្រូវតាមច្បាប់ដើម។
ថ្ងៃពុធ ៨រោច ខែជេស្ឋ ឆ្នាំខាល ចត្វាស័ក ព.ស ២៥៦៦
ខេត្តត្បូងឃ្មុំ ថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០២២
**<u>ក្រឡាបញ្ជី</u>**

[redacted]

**បានឃើញ**
**<u>ចៅក្រម</u>**

[redacted]



Scanned with CamScanner